


# ដំណើរទស្សនកិច្ចជាផ្លូវការ របស់លោកអភិបាល អូលីវីយេ

# នៅមណ្ឌលសកម្មភាពទន្លេបាសាក់





**១៣.១០.២០១៦**

ព្រះសហគមន៍សន្តីតេរេសា បឹងឈ្នូក

ព្រះសហគមន៍សន្តយ៉ូសែបទួលក្រសាំង

**១៤.១០.២០១៦**

ព្រះសហគមន៍សន្តយ៉ូសែប ស្អាង

ព្រះសហគមន៍សន្តយ៉ូសែប ពោធិបាន

( សំប៉ាន )

**១៥.១០.២០១៦**

ព្រះសហគមន៍សន្តអង់ទន់ កោះទាវ

**១៦.១០.២០១៦**

ព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ

# មាតិកា


១៣ តុលា ២០១៦

១ ព្រះសហាគមន៍សន្តិតេរេសា បឹងឈូក ...................................... ១-២

២ ព្រះសហាគមន៍សន្តយ៉ូសែប ទួលក្រសាំង .................................. ៣-៩

១៤ តុលា ២០១៦

១ ព្រះសហាគមន៍សន្តយ៉ូសែប ស្វាង ...................................... ១០-១២

២ ព្រះសហាគមន៍សន្តយ៉ូសែប ពោធិបាន (សំប៉ាន) ................. ១៣-១៩

១៥ តុលា ២០១៦

១ ព្រះសហាគមន៍សន្តអង់ទន់ កោះទារ ................................... ២០-២៦

១៦ តុលា ២០១៦

១ ព្រះសហាគមន៍សន្តយ៉ូសែប ជ្រៃធំ ...................................... ២៧-៣៨

# ព្រះសហគមន៍សន្តី តេរេសា

# បឹងឈូក








# ប្រវត្តិព្រះសហគមន៍សន្តីតេរេសា បឹងឈូក

ក្នុងកំឡុងឆ្នាំ១៩៦២ រហូតដល់១៩៧៥ មានគ្រីស្តបរិស័ទវៀតណាមមករស់នៅក្នុងខេត្តបាត់ដំបង។ ពួកគេមានកូនចៅជាច្រើននាក់ បានកើតនៅក្នុងប្រទេសកម្ពុជា។ នៅពេលប្រទេសកម្ពុជាមានសង្គ្រាម ជាពិសេសនៅសម័យប៉ុលពត គ្រីស្តបរិស័ទទាំងនោះត្រូវជម្លៀសឲ្យទៅប្រទេសវៀតណាមវិញ។

ក្នុងឆ្នាំ១៩៨១ បន្ទាប់ពីរបបប្រល័យពូជសាសន៍ប៉ុលពត បានដួលរលំ គ្រីស្តបរិស័ទដែលបានភៀសខ្លួនទៅប្រទេសវៀតណាម បានវិលត្រលប់មកប្រទេសកម្ពុជាវិញ និងមានខ្លះមករស់នៅភ្នំពេញ និងខេត្តកណ្តាល។

ពួកគេរស់នៅតាមរបៀបគ្រីស្តបរិស័ទដោយលួចលាក់ គឺជួបជុំគ្នានៅតាមផ្ទះ។ រហូតឆ្នាំ២០០៣ គ្រីស្តបរិស័ទបានខ្ចីឃ្លាំងដាក់ទំនិញមួយកន្លែង ដើម្បីធ្វើជាកន្លែងជួបជុំគ្នា។ គេជួបគ្នាក្នុងឃ្លាំងនោះរយៈពេល៥ឆ្នាំ។ ក្រោយព្រះសហគមន៍បានសម្រេចសុំទិញដីនោះពីម្ចាស់ឃ្លាំង។

ក្នុងឆ្នាំ២០០៨ ដោយមានការជួយឧបត្ថមពី អង្គការហ្វ្រង់ស៊ីស្កូ នៅអាមេរិក និងក្រុមបងប្រុស្រហ្វ្រង់ស៊ីស្កូ ព្រមទាំងមានការជួយជ្រោមជ្រែងពីគ្រីស្តបរិស័ទក្នុងនិងក្រៅប្រទេស ព្រះសហគមន៍ចាប់ផ្តើមកសាងព្រះវិហារថ្មី ដែលធ្វើពិធីបុណ្យឆ្លងក្នុងឆ្នាំ២០១៣។

គ្រីស្តបរិស័ទនៅព្រះសហគមន៍បឹងឈូក មានចំនួន ១០០គ្រួសារ ស្មើនឹង៣៥៦នាក់។

ក្រុមផ្សេងៗ៖ មានក្រុម បេះដូងព្រះយេស៊ូ ក្រុមសន្តីតេរេសា ក្រុមសង្គហៈ ក្រុមពិធីបុណ្យ ក្រុមអប់រំ ព្រមទាំងក្រុមយុវជន។

សាលា៖ សាលាមត្តេយ្យ និងថ្នាក់បឋមសិក្សា។





# ព្រះសហគមន៍សន្តយ៉ូសែប ទួលក្រសាំង



# ប្រវត្តិព្រះសហគមន៍សន្តយ៉ូសែប ទួលក្រសាំង

ព្រះសហគមន៍ទួលក្រសាំង កើតឡើងក្នុងឆ្នាំ ២០០៦ គឺដោយសារមានការមកតាំងទីលំនៅរបស់គ្រីស្តបរិស័ទ ដែលចេញពីចក្រអង្រែលើនៃរាជធានីភ្នំពេញ។ សព្វថ្ងៃមានគ្រីស្តបរិស័ទចំនួន ១៨ គ្រួសារ ស្មើរនឹង ៧០នាក់។

ក្រុមផ្សេងៗ៖ មានក្រុមបេះដូងព្រះយេស៊ូ ក្រុមសន្តីតេរេសា ក្រុមសង្គហៈ ក្រុមពិធីបុណ្យ ក្រុមអប់រំ ព្រមទាំងក្រុមយុវជន។

សាលារៀន៖ មានសាលាមត្តេយ្យ និងថ្នាក់បឋមសិក្សា ថ្នាក់ទី១ និងទី២។





## សកម្មភាពលោកអភិបាល ទស្សនកិច្ចនៅព្រះសហគមន៍សន្តយ៉ូសែប ទួលក្រសាំង









# សកម្មភាពលោកអភិបាល ថ្វាយអភិបូជា នៅព្រះសហគមន៍សន្តយ៉ូសែប ទួលក្រសាំង








# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាទស្សនកិច្ចនៅបឹងឈូកនិងនៅទួលក្រសាំង
# ថ្ងៃទី១៣ តុលា ២០១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះអត្ថបទគម្ពីរដំណឹងល្អ ណែនាំឲ្យយើងប្រុងប្រយ័ត្នខ្លួន។ ព្រះយេស៊ូមានព្រះបន្ទូលថា ***"ពួកបណ្ឌិតខាងវិន័យអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាបានបិទទ្វារមាគ៌ាមិនឲ្យគេចូលទៅស្គាល់ព្រះជាម្ចាស់។ អ្នករាល់គ្នាមិនត្រឹមតែមិនបានចូលខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងឃាត់អស់អ្នកដែលចង់ចូលមិនឲ្យគេចូលទៀតផង"*** គឺព្រះអង្គបន្ទោសក្រុមបូជាចារ្យ ក្រុមបណ្ឌិតខាងវិន័យ ដោយសារគេបានបិទផ្លូវ មិនឲ្យអ្នកដទៃបានស្គាល់ព្រះជាម្ចាស់។ ព្រះអង្គមានព្រះបន្ទូល **"ជាពិសេសបុព្វបុរសរបស់យើងបានប្រព្រឹត្តកំហុសយ៉ាងច្រើនដែលណែនាំឲ្យកូនចៅវង្វេង"**។ នេះក៏ជាបញ្ហារបស់យើងដែរថា ***"វេទនាហើយ"*** ដោយសារ យើងមិនត្រូវបិទផ្លូវដែលនាំឲ្យគេស្គាល់ព្រះជាម្ចាស់ទេ មានន័យថា បងប្អូនដែលជាឪពុកម្ដាយ ជាគណៈកម្មការ ជាអ្នកដឹកនាំព្រះសហគមន៍ មានតួនាទីសំខាន់ណាស់ក្នុងការណែនាំឲ្យអ្នកដទៃបានស្គាល់ព្រះជាម្ចាស់។

មានរឿងមួយជាឧទាហរណ៍ ក្នុងពេលគោរពទង់ជាតិ មានសិស្សម្នាក់មិនបានច្រៀងបទគោរពទង់ជាតិទេ ពេលបន្ទាប់លោកនាយកសាលាហៅសិស្សនោះ ទៅសួរពីមូលហេតុដែលមិនច្រៀង?។ សិស្សនោះជម្រាបទៅលោកនាយកថា ***"ខ្ញុំមិនច្រៀង ដោយសារខ្ញុំមិនដែលឃើញលោកគ្រូអ្នកគ្រូច្រៀង រួមទាំងលោកនាយកផង"***។ នេះបញ្ជាក់ឲ្យដឹងថា សិស្សយកគំរូតាមលោកគ្រូអ្នកគ្រូ។ ចំពោះយើងសព្វថ្ងៃ សេចក្ដីនេះសំខាន់ណាស់ គឺយើងជាឪពុកម្ដាយ ជាគណៈកម្មការ ជាបងប្រុសបងស្រី ជាអ្នកណែនាំព្រះសហគមន៍ ជាលោកបូជាចារ្យ ជាលោកអភិបាល គឺយើងត្រូវធ្វើជាគំរូដល់កូនៗរបស់យើង។ ពួកគេទទួលអ្វីៗទាំងអស់ពីយើង បើយើងណែនាំឲ្យគេស្រឡាញ់ព្រះយេស៊ូ ស្រឡាញ់ព្រះនាងម៉ារី នោះគេនឹងស្រឡាញ់ បើយើងណែនាំឲ្យគេមានទម្លាប់ចូលព្រះវិហាររាល់ថ្ងៃ នោះគេនឹងបន្តទម្លាប់នេះតទៅទៀត ប៉ុន្តែប្រសិនបើយើងមិនដែលចូលព្រះវិហារ និងមិនដែលអធិដ្ឋានទេនោះ យូរៗទៅណែនាំឲ្យកូនៗយើងច្រឡំផ្លូវ។

យើងជាគណៈកម្មការធ្លាប់និយាយថា ក្នុងព្រះសហគមន៍យើងមានយុវជនយុវនារីខ្លះវង្វេងផ្លូវ ដោយសារគេមិនដែលចូលព្រះវិហារ គេបានប្រព្រឹត្តអំពើខុសនឹងសីលធម៌... ប៉ុន្តែយើងដឹងហើយថាព្រះយេស៊ូយាងមកណែនាំឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក គឺស្រឡាញ់មនុស្សទាំងអស់ ជាពិសេសកូនក្មេង និងយុវជនយុវនារី ដែលគេកំពុងមានការលូតលាស់ខាងរាងកាយ និងចិត្តគំនិត ព្រះយេស៊ូសព្វព្រះហឫទ័យឲ្យយើងធ្វើជាគំរូដល់គេ។ ដូចយើងបានស្ដាប់អត្ថបទទីមួយហើយថា ***"សូមជម្រាបមកបងប្អូនជាប្រជារាស្ត្រដ៏វិសុទ្ធ (បឹងឈូក និងទួលក្រសាំង) ដែលជឿលើព្រះយេស៊ូគ្រីស្ត សូមព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រីស្តប្រណីសន្ដោស ប្រទានសេចក្ដីសុខសាន្តដល់បងប្អូន ដើម្បីឲ្យបងប្អូនស្គាល់***

*ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់"* គឺព្រះជាម្ចាស់យាងមកដើម្បីឲ្យយើងទទួលសេចក្ដីសុខសាន្ត ឲ្យយើងទទួលយកព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ មានន័យថា ឲ្យយើងទទួលស្វាគមន៍ព្រះយេស៊ូដែលស្រឡាញ់យើង ដោយឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក។ ***"បងប្អូនជាប្រជារាស្ត្រដ៏វិសុទ្ធ"*** មានន័យថា យើងទៅជាវិសុទ្ធ ដោយសារយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ដោយសារយើងស្ថិតនៅជាប់ជាមួយព្រះយេស៊ូ ដែលបានប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យយើង ដូច្នេះយើងត្រូវតែថែរក្សាជំនឿនេះ ដើម្បីរស់មួយជីវិត យើងអាចធ្វើដំណើររួមជាមួយព្រះយេស៊ូបាន។

ថ្ងៃនេះ ព្រះយេស៊ូបានជ្រើសរើសយើងឲ្យទៅជាពន្លឺមួយ គឺនាំសេចក្ដីសុខសាន្តរបស់ព្រះអង្គដល់អស់បងប្អូនដែលរស់នៅជុំវិញយើង។ យើងមិនរស់នៅតែក្នុងចំណោមគ្នាយើងជាគ្រីស្តបរិស័ទប៉ុណ្ណោះ តែយើងរស់នៅក្នុងសង្គមដែលមានគ្រប់សាសនា គ្រប់សញ្ជាតិ គ្រប់ប្រភេទមនុស្ស...។ ពេលយើងមានអំណរសប្បាយពេលយើងមានទុក្ខលំបាក ព្រះយេស៊ូសូមឲ្យយើងជាគ្រីស្តបរិស័ទដែលបានទទួលសេចក្ដីសង្ឃឹម សេចក្ដីសុខសាន្តពីព្រះអង្គផ្ទាល់គិតថា **តើត្រូវធ្វើដូចម្ដេចដើម្បីផ្ដល់សេចក្ដីសង្ឃឹម សេចក្ដីសុខសាន្តនោះដល់បងប្អូនឯទៀតៗ? តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យយើងទៅជាពន្លឺតូចមួយសម្រាប់អ្នកដទៃ?** យើងកំពុងរស់នៅក្នុងទីក្រុងមួយដែលមានការរីកចម្រើនខ្លាំងទៅៗ ក៏ប៉ុន្តែមានមនុស្សជាច្រើនដែលកំពុងរងទុក្ខវេទនាដែរ ដូច្នេះយើងទទួលបេសកកម្មយ៉ាងពិសេសមួយ គឺណែនាំសេចក្ដីសុខសាន្តដែលយើងទទួលពីព្រះយេស៊ូ ជូនដល់បងប្អូនដែលកំពុងរងទុក្ខលំបាកទាំងនោះ។ ត្រូវចាប់អារម្មណ៍ថា យើងកំពុងរស់នៅជាក្រុមគ្រួសារតែមួយជាមួយបងប្អូនពុទ្ធបរិស័ទ ជាមួយបងប្អូនខ្មែរ ជាមួយបងប្អូនវៀតណាម និងជាមួយបងប្អូនឯទៀតៗដែរ។

យើងជាគ្រីស្តបរិស័ទ បានទទួលកម្លាំងពីព្រះយេស៊ូផ្ទាល់។ សូមព្រះជាម្ចាស់ ជាព្រះបិតា និងព្រះអម្ចាស់ព្រះយេស៊ូគ្រីស្តប្រណីសន្ដោស និងប្រទានសេចក្ដីសុខសាន្តដល់បងប្អូនទាំងអស់គ្នា។ កម្លាំងដែលយើងបានទទួលពីព្រះយេស៊ូ ណែនាំឲ្យយើងចែករំលែកសេចក្ដីសុខសាន្តដល់អ្នកដទៃ។ យើងត្រូវការគិតថា **តើយើងណែនាំសេចក្ដីសុខសាន្តអ្វីខ្លះសម្រាប់ក្រុមគ្រួសាររបស់យើង? និងសម្រាប់បងប្អូនឯទៀតៗ?** ដើម្បីទទួលជោគជ័យក្នុងកិច្ចការនេះ ព្រះយេស៊ូបានសូមឲ្យយើងអធិដ្ឋាន ដូច្នេះសូមបងប្អូនរកពេលវេលាដើម្បីអធិដ្ឋានជារៀងរាល់ថ្ងៃ សូមព្រះជាម្ចាស់គង់នៅជាមួយយើង ឲ្យយើងមានកម្លាំងទៅមុខ ឲ្យយើងទៅជាគំរូសម្រាប់អ្នកដទៃ ឲ្យបងប្អូននៅជុំវិញយើងចេះស្រឡាញ់គ្នា ដោយសារយើងជាគំរូសម្រាប់ពួកគេ ដោយយើងស្រឡាញ់គេជាក្រុមគ្រួសារតែមួយ។ យើងអាចកសាងក្រុមគ្រួសារតែមួយ នៅកន្លែងដែលយើងរស់នៅទោះបីយើងមានគ្នាតិចក៏ដោយ ដោយសារយើងបានទទួលកម្លាំងយ៉ាងពិសេសពីព្រះយេស៊ូផ្ទាល់។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់យើងខ្ញុំទាំងអស់គ្នាសូមឲ្យយើងខ្ញុំរួមគ្នាកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត ជាព្រះសហគមន៍ដែលសម្ដែងធម៌មេត្តាករុណារបស់ព្រះបិតានៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែងផង។ អាម៉ែន។

# BÀI GIẢNG CỦA ĐỨC CHA OLIVIER

## Thăm mục vụ Boeung Chhuk và Tual Crsang

## Ngày 13/10/2016

Anh chị em thân mến!

Bài Phúc Âm hôm nay nhắc nhở chúng ta phải luôn cẩn trọng. Đức Giê-su phán rằng: "Khốn cho các ngươi hỡi những nhà thông luật! Các ngươi đóng cửa không cho người khác nhận biết Thiên Chúa. Không chỉ bản thân các ngươi không vào mà các ngươi còn ngăn cản người khác không cho họ vào". Ngài lên án các tư tế, các nhà thông luật vì họ ngăn cản không để cho người khác nhận biết Thiên Chúa. Ngài nhấn mạnh cách đặc biệt: "Khốn cho các ngươi", vì tổ phụ của họ đã sai lỗi quá nhiều, khiến cho con cháu họ mắc sai lầm. Đây cũng là vấn đề của chúng ta: ta không nên cản đường người khác đến gặp Chúa. Nghĩa là, anh chị em là những người  làm cha mẹ, Ban hành giáo, người dẫn dắt giáo họ có vai trò rất quan trọng trong việc đưa người khác đến với Chúa.

Có một câu chuyện kể về việc chào cờ. Trong khi chào cờ có một học sinh không chịu hát quốc ca. Sau đó, vị hiệu trưởng gọi em đó lại và hỏi lí do tại sao không hát? Em trả lời rằng: "Vì em không bao giờ thấy thầy và thầy cô khác hát nên em cũng không hát". Điều này cho thấy, học sinh luôn bắt chước theo thầy cô. Điều này cũng hết sức quan trọng đối với chúng ta. Vì chúng ta là cha mẹ, Ban hành giáo, tu sĩ nam nữ, là người dẫn dắt, là Linh mục, Giám Mục, chúng ta phải làm gương cho con cái của mình. Tất cả những gì con cái nhận được đều từ chúng ta. Nếu ta làm gương con cái sẽ biết yêu mến Đức Giê-su, Đức Mẹ, biết đi lễ đều đặn. Nhưng nếu chúng ta không đi nhà thờ, không cầu nguyện, thì lâu dần con cái chúng ta cũng sẽ nguội lạnh, lạc đạo.

Hiện nay, chúng ta thường nói, có nhiều người trẻ lạc đạo, xa nhà thờ, hành động thiếu đạo đức,… Nhưng ta phải biết rằng, Đức Giê-su xuống thế là để dạy ta biết yêu thương mọi người – đặc biệt là trẻ em, giới trẻ - là những người đang phát triển cả về thể chất lẫn tinh thần, Người cũng muốn ta làm gương cho họ. Cũng như trong bài đọc một: "Xin gởi lời chào đến dân Thánh (Boeung Chhuk và Tual Crsang) là những người đã tin vào Đức Giê-su. Nguyện xin Thiên Chúa là Cha chúng ta và Đức Giê-su Ki-tô, Chúa chúng ta, ban bình an cho anh em, để anh em nhận biết hồng ân của Thiên Chúa". Thiên Chúa ngự đến để ban bình an cho chúng ta, ban ơn lành

cho chúng ta, là cho ta được đón nhận Đức Giê-su, Đấng yêu thương chúng ta, bởi vì chúng ta biết yêu thương nhau. “Anh em là dân Thánh”, nghĩa là chúng ta nên thánh nhờ chịu phép rửa, nhờ chúng ta kết hợp với Đức Giê-su, Đấng trao ban sự sống cho chúng ta. Bởi vậy, chúng ta phải giữ gìn đức tin này luôn, để cả đời ta luôn đồng hành với Người.

Hôm nay, Đức Giê-su chọn chúng ta để trở thành ánh sáng mang bình an của Người đến với những anh em đang sống quanh ta. Chúng ta không chỉ sống gói gọn trong cộng đồng người công giáo, nhưng chúng ta đang sống trong một xã hội đa tôn giáo, đa quốc tịch, đa chủng loại người,… Trong mọi hoàn cảnh, vui buồn hay sướng khổ, với hành trang là hy vọng và bình an của Đức Ki-tô, ta phải làm sao để mang hy vọng và bình an đến cho người khác. Phải làm sao để ta trở thành đốm sáng cho mọi người. Chúng ta đang sống trong một thành phố đang phát triển ngày càng mạnh, nhưng cũng có nhiều người đang đau khổ. Vậy nên chúng ta có một sứ mệnh vô cùng đặc biệt là mang bình an của Đức Ki-tô cho những người anh em đang đau khổ đó. Nên lưu ý rằng, chúng ta đang sống trong một đại gia đình với thành viên là: phật tử, người Khmer, người Việt và cả những người anh em khác nữa.

Người Ki-tô hữu đón nhận sức mạnh từ chính Đức Ki-tô. Nguyện xin Chúa Cha và Đức Giê-su, Chúa chúng ta, ban bình an cho tất cả anh chị em. Sức mạnh mà chúng ta đón nhận từ Đức Ki-tô thúc đẩy chúng ta mang Đức Ki-tô đến cho người khác. Cần phải tự hỏi xem, chúng ta phải làm gì để đem lại bình an cho chính gia đình của chúng ta? Cho những người xung quanh? Để được thành công, Đức Giê-su mời gọi chúng ta hãy cầu nguyện. Xin anh chị em hãy dành thời gan cầu nguyện mỗi ngày, xin Thiên Chúa ở cùng chúng ta, ban sức mạnh để ta tiếp bước, trở thành mẫu gương cho mọi người, làm cho những người sống quanh ta biết yêu thương nhau vì chúng ta làm gương cho họ, yêu thương họ như một gia đình. Chúng ta có thể xây dựng một đại gia đình ngay tại nơi chúng ta đang sống, dẫu cho chúng ta có ít người cũng không sao vì chúng ta có được sức mạnh của chính Đức Ki-tô.

Hôm nay chúng ta cùng nhau tạ ơn Thiên Chúa,xin Người ban phúc cho tất cả chúng ta. Xin cho chúng ta biết cộng tác với nhau xây dựng Hội Thánh của Đức Ki-tô, là một Hội Thánh tỏ hiện Lòng Thương Xótcủa Đức Chúa Cha mọi lúc, mọi nơi. Amen.

# ព្រះសហគមន៍សន្តយ៉ូសែប ស្អាង








# ប្រវត្តិព្រះសហគមន៍សន្តយ៉ូសែប ស្អាង

ព្រះសហគមន៍ស្អាង គឺជាព្រះសហគមន៍ដ៏ចំណាស់មួយដែលគ្រីស្តបរិស័ទបានកសាងតាំងពីមុនសម័យសង្គ្រាមក្នុងកំឡុងឆ្នាំ១៩៧០មកម្ល៉េះ។ ក្នុងសម័យខ្មែរក្រហម គ្រីស្តបរិស័ទបានភៀសខ្លួនទៅប្រទេសវៀតណាម រហូតដល់ឆ្នាំ១៩៧៩-១៩៨០ គ្រីស្តបរិស័ទបានមកតាំងទីលំនៅ នៅស្អាងនេះវិញ តែមិនហ៊ានចេញមុខទេដោយសារតែក្នុងសម័យនោះ គ្រីស្តបរិស័ទបានរងទុក្ខលំបាកជាច្រើន។ គ្រីស្តបរិស័ទមួយចំនួន ត្រូវគេសម្លាប់ក្នុងពេលសង្គ្រាម ពួកគេផ្លាស់ប្តូរទីកន្លែងរស់នៅជាញឹកញាប់ គេប្រណិបត្តិជំនឿដោយលួចលាក់។ រហូតដល់ឆ្នាំ១៩៩៣ ទើបគេមានសេរីភាពឡើងវិញ នៅឆ្នាំ២០០០ ដោយមានការសហការគ្នា គេបានកសាងព្រះវិហារមួយ តែក្រោយមកក៏ចាស់ទ្រុឌទ្រោម។ នៅក្នុងឆ្នាំ២០១៤ បានកសាងព្រះវិហារថ្មី ជាព្រះវិហារសព្វថ្ងៃនេះ។

គ្រីស្តបរិស័ទក្នុងព្រះសហគមន៍ស្អាង សព្វថ្ងៃមានចំនួន ១៣៦គ្រួសារ ស្មើរនឹងចំនួន ៤៨០នាក់។

ក្រុមផ្សេងៗ៖ គណៈកម្មការសង្គហៈ គណៈកម្មការពិធីបុណ្យ គណៈអប់រំជំនឿ ក្រុមសន្តិថេរេសា ក្រុម Legioម៉ារី ក្រុមព្រះបេះដូងព្រះយេស៊ូ ក្រុមចំរៀង និងក្រុមរបាំ។

- មានសាលាមតេយ្យ មានបឋមសិក្សា ថ្នាក់ទី១ និងទី២
- សកម្មភាពរាល់ថ្ងៃនៅព្រះសហគមន៍រួមមានៈ
    - កម្មវិធីរៀនអប់រំជំនឿនៅពេលរសៀលរាល់ថ្ងៃ។
    - ម៉ោង៤ ក្រុម Legioម៉ារី អធិដ្ឋានរាល់ថ្ងៃ ។
    - ម៉ោង៥ រៀន ព្រះគម្ពីដំណឹងល្អ។
    - នៅថ្ងៃព្រហស្បត្តិ៍ ក្រុមសង្គហៈរួមគ្នាសូត្រធម៌អធិដ្ឋាននៅពេលល្ងាច។
    - ថ្ងៃសុក្រ ក្រុមបេះដូងព្រះយេស៊ូ សូត្រធម៌អធិដ្ឋាន និងប្រជុំគ្នា។
    - ថ្ងៃសៅរ៍ ក្រុមសន្តីថេរេសា សូត្រធម៌អធិដ្ឋាន និងប្រជុំគ្នានៅព្រះវិហារ។
    - ថ្ងៃអាទិត្យ ថ្វាយអភិបូជា(បើមានបូជាចារ្យ) តែបើអត់គឺគ្រីស្តបរិស័ទរួមគ្នាអធិដ្ឋាន។





# សកម្មភាពលោកអភិបាល ទស្សនកិច្ចនៅព្រះសហាគមន៍សន្តយ៉ូសែប ស្អាង














ព្រះសហគមន៍សន្តយ៉ូសែប ពោធិបាន (សំប៉ាន)

# ប្រវត្តិព្រះសហគមន៍សន្តយ៉ូសែប ពោធិបាន (សំប៉ាន)

ព្រះសហគមន៍នេះ ជាកន្លែងដែលមានវ័យចំណាស់មួយ គឺបានកសាងឡើងតាំងពីមុនសង្គ្រាមស៊ីវិល ឆ្នាំ១៩៧០មកម្ល៉េះ។ ក្នុងពេលសង្គ្រាម គ្រីស្តបរិស័ទបានភៀសខ្លួនទៅវៀតណាម រហូតដល់ខ្មែរក្រហមដួលរលំគេត្រលប់មកវិញ និងបានចាប់ផ្តើមសារជាថ្មីក្នុងទស្សវត្សទី៩០។ គ្រីស្តបរិស័ទសព្វថ្ងៃនេះមានប្រមាណជា៥៨គ្រួសារ។

ក្រុមផ្សេងៗ ៖ មានក្រុមចំរៀង ក្រុមពិធីបុណ្យ ក្រុមសង្គហៈ ក្រុមអប់រំជំនឿ ក្រុមតេរេសា ក្រុមបេះដូងព្រះយេស៊ូ ។

សាលារៀន ៖ សាលាមត្តេយ្យ មានថ្នាក់បឋមសិក្សា ថ្នាក់១ដល់ទី៣។

















សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅ ព្រះសហគមន៍ពោធិបាន (សំប៉ាន)

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាទស្សនកិច្ចនៅស្អាងនិងនៅពោធិ៍បាន
# ថ្ងៃទី១៤ តុលា ២០១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្តាប់ព្រះបន្ទូលដ៏សំខាន់មួយ អំពីការរស់នៅរបស់យើងគឺ ***"អ្នករាល់គ្នាកុំខ្លាចអ្វីឡើយ ព្រោះអ្នករាល់គ្នាមានតម្លៃលើសចាបទៅទៀត"***។ ព្រះបន្ទូលនេះ លើកទឹកចិត្តយើងទាំងអស់គ្នា ***"កុំឲ្យខ្លាចអី"*** ដ្បិតយើងមានតម្លៃណាស់។ យើងមានតម្លៃចំពោះព្រះជាម្ចាស់ ចំពោះព្រះយេស៊ូដែលស្រឡាញ់យើង។ ព្រះយេស៊ូស្គាល់យើងយ៉ាងច្បាស់ និងព្រះអង្គធ្វើដំណើររួមជាមួយយើង។ នៅឆ្នាំ១៩៧០បងប្អូនបានភៀសខ្លួនទៅប្រទេសវៀតណាម និងនៅឆ្នាំ១៩៧៩ បងប្អូនបានត្រឡប់មកវិញដើម្បីកសាងព្រះសហគមន៍របស់ខ្លួននៅទីនេះ(ស្អាងនិងពោធិ៍បាន)។ បងប្អូនបានឆ្លងកាត់ទុក្ខលំបាកយ៉ាងច្រើន ដើម្បីកសាងជីវិតសារជាថ្មី និងដើម្បីថែរក្សាជំនឿរបស់យើង។

សព្វថ្ងៃបងប្អូនបានទទួលផ្លែយ៉ាងច្រើន ដូចមានចែងក្នុងអត្ថបទទីមួយថា ***"ព្រះជាម្ចាស់បានតម្រូវយើងទុកជាមុន ឲ្យបានទៅជាប្រជារាស្ត្ររបស់ព្រះអង្គ ហើយទ្រង់សម្រេចគ្រប់កិច្ចការតាមព្រះហឫទ័យព្រះអង្គ"*** គឺអ្វីៗទាំងអស់ដែលបានកើតឡើងក្នុងការរស់នៅរបស់បងប្អូន សុទ្ធតែជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលព្រះអង្គស្រឡាញ់បងប្អូន។ ពេលយើងឃើញមានកូនក្មេងច្រើនបែបនេះ ពេលយើងឃើញមានយុវជនយុវនារីដែលពោរពេញដោយកម្លាំងបែបនេះ ណែនាំឲ្យយើងយល់ភ្លាមថា នេះគឺជាផ្លែកើតចេញពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានដៅលើថ្ងៃដែលបងប្អូនទទួលអគ្គសញ្ញាលាបថ្វាស។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលសព្វថ្ងៃបង្ហាញផ្លែ បានណែនាំឲ្យបងប្អូនប្រែចិត្តគំនិតហើយគិតដល់អនាគតកូនៗ ដោយបញ្ជូនគេកាន់តែច្រើនឡើងៗទៅទទួលការអប់រំនៅសាលារៀន។ លោកតាលោកយាយ និងឪពុកម្តាយទាំងអស់បានបំពេញតួនាទីយ៉ាងសកម្ម គឺបានអប់រំកូនចៅឲ្យគេស្រឡាញ់ព្រះយេស៊ូ ស្រឡាញ់ព្រះសហគមន៍ និងស្រឡាញ់ការសិក្សា ដើម្បីអនាគតរបស់ខ្លួនគេផ្ទាល់។

ពិតមែន យើងជាគណៈកម្មការព្រះសហគមន៍ គឺយើងមានតួនាទីណែនាំឲ្យកូនៗរបស់យើងបានទទួលព្រះបន្ទូលរបស់ព្រះយេស៊ូ ឲ្យកូនៗចេះស្រឡាញ់គ្នាទៅវិញទៅមក។ យើងមានតួនាទីបង្ហាញសេចក្តីស្រឡាញ់បង្ហាញពីរបៀបដែលយើងសហការគ្នា ពីរបៀបដែលយើងគោរពគ្នានិងពីរបៀបដែលយើងរួមគ្នាបង្កើតព្រះសហគមន៍ពិតៗរបស់ព្រះយេស៊ូ។ យើងមានតួនាទីណែនាំឲ្យបងប្អូនទាំងអស់ដែលនៅជុំវិញយើងមានសេចក្តីស្រឡាញ់ តាមរយៈយើងដែលចេះស្រឡាញ់គ្នាទៅវិញទៅមក រស់នៅក្នុងព្រះសហគមន៍ជាគ្រួសារមួយដ៏សុខសាន្តប្រកបដោយសេចក្តីស្រឡាញ់។

ថ្ងៃនេះយើងនឹកឃើញដល់ជីវិត ដែលយើងបានទទួលជីវិតពីព្រះជាម្ចាស់ យើងបានឆ្លងកាត់ទុក្ខលំបាកដ៏ច្រើនដោយការតស៊ូ ដោយសេចក្តីស្រឡាញ់ ដែលយើងមានចំពោះគ្នានិងណែនាំឲ្យព្រះសហគមន៍របស់

យើងរីកចម្រើន។ យើងត្រូវតែបន្តថែរក្សាជំនឿលើព្រះយេស៊ូ ដែលជាព្រះអំណោយទានពីព្រះជាម្ចាស់ យើងត្រូវណែនាំឲ្យកូនចៅរបស់យើងចេះអធិដ្ឋាន និងចេះស្រឡាញ់គ្នាទៅវិញទៅមក។ ម្យ៉ាងទៀត យើងក៏ត្រូវរិះគិតពីរបៀបសម្ដែងធម៌មេត្តាករុណា ដែលមានច្រើនវិស័យដូចជា៖ ការអប់រំ សុខភាព ជនពិការ ពលករ អ្នកចំណាកស្រុក ការណែនាំអ្នកតូចតាចឲ្យចូលក្នុងសង្គម និងទំនាក់ទំនងអន្តរសាសនាជាដើម ដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់បានទៅដល់គ្រប់ទីកន្លែង។ សរុបមក គឺយើងត្រូវថែរក្សាទាំងជំនឿ និងទាំងការសម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ជីវិតរបស់យើង មានតម្លៃណាស់ ទោះបីយើងមានទុក្ខលំបាកប៉ុន្តែយើងមានព្រះជាម្ចាស់គង់នៅជាមួយណែនាំឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍ដែលមានជីវិត មានពន្លឺយ៉ាងពិសេសនៅក្នុងភូមិរបស់យើង ឲ្យយើងបង្ហាញសេចក្ដីស្រឡាញ់។

សូមអរព្រះគុណព្រះជាម្ចាស់សូមព្រះអង្គជួយយើងខ្ញុំថែមទៀត ចំពោះជីវិត ចំពោះសេចក្ដីស្រឡាញ់ដែលយើងខ្ញុំបានទទួលពីព្រះអង្គ។ សូមឲ្យព្រះសហគមន៍ទាំងមូល ទាំងលោកបូជាចារ្យដែលជាគង្វាល ទាំងគណៈកម្មការ ទាំងយុវជនយុវនារី រួមគ្នាកសាងព្រះសហគមន៍របស់ព្រះយេស៊ូ ជាព្រះសហគមន៍នៃសេចក្ដីស្រឡាញ់ និងធម៌មេត្តាករុណា។ អាម៉ែន។

**BÀI GIẢNG CỦA ĐỨC CHA OLIVIER**

**Thăm mục vụ Saang và Tam Bản**

**Ngày 14/10/2016**

Anh chị em thân mến!

Hôm nay chúng ta được nghe một đoạn Lời Chúa hết sức quan trọng hướng dẫn cách sống của chúng ta. Đó là : "Anh em đừng lo vì anh em đáng giá hơn chim sẻ". Những lời này nâng đỡ chúng ta, "đừng sợ" vì chúng ta đáng giá. Chúng ta đáng giá đối với Thiên Chúa và Đức Giê-su, Đấng yêu thương chúng ta. Đức Giê-su biết rõ và đồng hành với chúng ta. Năm 1970, anh chị em đã phải chạy về Việt Nam. Năm 1979, anh chị em đã quay lại xây dựng Giáo hội nơi đây ( Saang và Tam Bản). Anh chị em dã trải qua nhiều đau khổ để dựng xây đời sống mới và gìn giữ đức tin của mình.

Hôm nay, anh chị em đã nhận được nhiều hoa trái, như trong bài đọc 1 có viết: "Thiên Chúa đã chọn ta từ trước để trở thành Dân riêng theo ý định của Người". Tất cả những gì xảy ra trong cuộc đời của anh chị em đều là Thánh ý của Thiên Chúa, Đấng luôn yêu thương anh chị em. Khi nhìn thấy nhiều trẻ em, nhiều thanh niên tràn đầy sức sống như thế này, khiến chúng ta nhận ra ngay đây chính là hoa trái của Chúa Thánh Thần, đã dậy lên kể từ ngày anh chị em được đón nhận trong ngày lãnh Bí tích Thêm sức. Chúa Thánh Thần đang hoạt động khiến anh chị em nghĩ đến tương lai con em của mình mà gởi chúng tới đây để học. Ông bà cha mẹ của các em nhỏ đây đã chu toàn nhiệm vụ một cách tích cực, đó là dạy cho các em biết yêu mến Đức Giê-su, yêu mến Giáo Hội, yêu thích học tập vì tương lai của mình.

Đúng vậy, chúng ta, Ban hành giáo, có nhiệm vụ hướng dẫn cho con em mình biết đón nhận Lời Chúa và biết yêu thương nhau. Chúng ta cũng có nghĩa vụ làm gương bác ái, đoàn kết, tôn trọng lẫn nhau, cùng nhau xây dựng Hội Thánh đích thực của Đức Giê-su. Chúng ta cũng có nghĩa vụ làm gương về 1 giáo hội bình anvới tràn đầy yêu thương cho những người anh em hàng xóm của chúng ta.

Hôm nay, chúng ta cũng nhớ đến sự sống mà chúng ta được đón nhận từ Thiên Chúa. Chúng ta đã vượt qua muôn vàn thử thách với sự kiên trì và yêu

thương, khiến cho giáo hội được phát triển. Chúng ta phải tiếp tục gìn giữ đức tin vào Đức Giê-su, là món quà của Thiên Chúa. Chúng ta phải hướng dẫn cho con cháu biết cầu nguyện và yêu thương nhau. Ngoài ra, cũng cần phải suy nghĩ xem phải làm cách nào để thực thi bác ái, với nhiều hình thức như: giáo dục, sức khỏe, người khuyết tật, nhân công, người tị nạn, hội nhập cộng đồng và đối thoại liên tôn,…để cho lòng thương xót của Chúa đến khắp mọi nơi. Tóm lại, chúng ta cần phải gìn giữ đức tin, thực thi Lòng Thương Xót Chúa. Cuộc đời của chúng ta rất có giá trị. Dù chúng ta gặp nhiều đau khổ, nhưng có Thiên Chúa ở cùng, dẫn dắt để Giáo Hội trở thành một Giáo Hội sống động, chiếu tỏa ánh sáng đặc biệt trong xóm làng của chúng ta nhờ tình yêu.

Xin tạ ơn Thiên Chúa! Xin Ngài trợ giúp sự sống và tình yêu đã ban cho chúng ta. Mong rằng toàn thể giáo hội, gồm linh mục, là chủ chăn, Ban hành giáo, giới trẻ cùng nhau dựng xây Hội Thánh của Đức Giê-su trở thành 1 Hội Thánh của Tình yêu và Giàu Lòng Thương Xót. Amen.

# ព្រះសហគមន៍សន្តអង់ទន់ កោះធាច








# ប្រវត្តិព្រះសហគមន៍សន្តអង់ទន់ កោះទាវ

ព្រះសហគមន៍កោះទាវ បានកើតឡើងតាំងពីមុនសង្គ្រាមស៊ីវិលនៅកម្ពុជាមកម្លេះ គឺមុនឆ្នាំ១៩៧០។ ក្នុងសម័យខ្មែរក្រហម គ្រីស្តបរិស័ទទាំងអស់បានចាក់ចេញទៅប្រទេសវៀតណាម រហូតដល់ទស្សវត្ស ឆ្នាំ៨០ ទើបត្រលប់មកកម្ពុជាវិញ។ ពេលត្រលប់មកវិញមិនទានហ៊ានប្រកាសខ្លួនជាគ្រីស្តបរិស័ទទេ គឺត្រូវលាក់ខ្លួនសិន រហូតដល់មានការទទួលស្គាល់ពីរដ្ឋាភិបាលក្នុងទស្សវត្សទី៩០។ នៅឆ្នាំ១៩៩៨ បានកសាងព្រះវិហារមួយ។ ក្រោយដោយសារតែព្រះវិហារនោះចាស់ទ្រុឌទ្រោម មិនអាចបន្តសកម្មភាពទៀតបាន។ ព្រះសហគមន៍បានចាប់ផ្តើសន្សំប្រាក់ ដោយចូលរួមពីគ្រីស្តបរិស័ទនៅកោះទាវ និងមានជំនួយខ្លះពីខាងវៀតណាម ដើម្បីកសាងព្រះវិហារឡើងវិញនៅឆ្នាំ២០០៣ រហូតដល់២០១០ ទើបរួចរាល់។ សព្វថ្ងៃ គឺប្រើព្រះវិហារនោះ។ ព្រះសហគមន៍កោះទាវ មានគ្រីស្តបរិស័ទចំនួនប្រមាណ ៦០នាក់។

ក្រុមផ្សេងៗ៖ ក្រុមបេះដូងព្រះយេស៊ូ ក្រុម Legio ក្រុមសន្តីតេរេសា និងក្រុមកាយរិទ្ធ ទើបតែចាប់ផ្តើមថ្មី។ គណៈកម្មការសង្គហៈ គណៈកម្មការពិធីបុណ្យ និងគណៈកម្មការអប់រំជំនឿ។

- មានសាលាមតេយ្យ និងសាលាអក្ខរកម្មភាសាខ្មែរ។
- សកម្មភាពជាប្រចាំថ្ងៃរួមមានៈ
  - អធិដ្ឋានសូត្រផ្គាំព្រះមាលាពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍រយៈពេលមួយម៉ោងក្នុងមួយថ្ងៃ។
  - ការប្រជុំគណៈកម្មការ តាមសកម្មភាព ឬកម្មវិធីផ្សេងៗ ។
  - ថ្ងៃអាទិត្យ ថ្វាយអភិបូជា និងបង្រៀនអប់រំជំនឿ។











សកម្មភាពលោកអភិបាល ទស្សនកិច្ចនៅព្រះសហគមន៍សន្តអង់ទន់ កោះទាវ





# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាចារ្យទស្សនកិច្ចនៅកោះធាច
# ថ្ងៃទី១៥ តុលា ២០១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្តាប់អត្ថបទទីមួយ ជាលិខិតរបស់សន្តៈប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងអេភេសូ ថា ***"ព្រះយេស៊ូ ជាសិរសារបស់ព្រះសហគមន៍ដែលជាព្រះកាយព្រះគ្រីស្ត ហើយព្រះគ្រីស្តផ្ទាល់បានបំពេញគ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់"***។ ពេលស្តាប់អត្ថបទនេះ ណែនាំឲ្យយើងយល់ថាយើងជាព្រះកាយរបស់ព្រះគ្រីស្ត ហើយយើងមានមោទនភាពដោយយើងជាព្រះកាយព្រះគ្រីស្ត ដែលមានព្រះយេស៊ូជាព្រះសិរសា។ ក្នុងព្រះវិហារនេះ មានរូបមរណសាក្សីពីប្រទេសវៀតណាមចំនួន១១៧នាក់។ ពេលឃើញភ្លាមណែនាំឲ្យយើងនឹកដល់ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ដោយមានព្រះយេស៊ូជាព្រះសិរសា និងដោយមានប្រជារាស្ត្រព្រះជាម្ចាស់ដែលបានលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីព្រះសហគមន៍ជាអវយវៈ។ អវយវៈនៃព្រះកាយព្រះគ្រីស្ត គឺជាគ្រីស្តបរិស័ទទាំងអស់គ្នាដែលមានបងប្រុសបងស្រី មានលោកអភិបាល លោកបូជា-ចារ្យ សាសនទូតជាដើម... ក្នុងនោះមានលោកទែអូហ្វាប៉ែរណា ដែលសព្វថ្ងៃមានធាតុនៅក្នុងព្រះវិហារជ្រៃធំ។ លោកត្រូវបានគេចាប់យកទៅឃុំឃាំងអស់ចំនួនបីថ្ងៃ និងក្រោយមកគេសម្លាប់។ មានលោកប៉ូណាម ដែលត្រូវគេសម្លាប់ដោយកាត់ក។ អ្នកសម្លាប់លោក គឺជាមិត្តសម្លាញ់របស់លោក។ នៅពេលសម្លាប់លោកប៉ូណាមមិត្តសម្លាញ់នោះទើសទាល់ក្នុងចិត្តខ្លាំងណាស់ គេបានផឹកស្រាយ៉ាងច្រើនឲ្យស្រវឹង រួចហើយគេកាប់ប្រាំពីរដងទើបដាច់ក្បាលចេញពីដងខ្លួន។ ពេលឃើញបែបនេះ បញ្ជាក់យ៉ាងច្បាស់ថា ព្រះសហគមន៍របស់យើងពិតមែនមានព្រះយេស៊ូដែលត្រូវគេធ្វើគុតជាព្រះសិរសា និងមានប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែលបានបូជាជីវិតជាអវយវៈនៃព្រះកាយព្រះគ្រីស្ត។ យើងដែលជាបងប្រុសបងស្រី ជាលោកឪពុក ជាគ្រីស្តបរិស័ទ យើងជារូបកាយរបស់ព្រះគ្រីស្ត យើងមានព្រះយេស៊ូជាសិរសា ដែលណែនាំយើង ដែលបំភ្លឺយើង ដែលផ្តល់សេចក្តីក្លាហាន និងប្រទានឲ្យយើងមានជំនឿរឹងមាំ។

សន្តៈប៉ូលបានអធិដ្ឋាន អង្វរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណឲ្យបងប្អូនមានប្រាជ្ញា និងឲ្យបងប្អូនស្គាល់ព្រះអង្គយ៉ាងច្បាស់។ ថ្ងៃនេះ ខ្ញុំមកក៏ដើម្បីអធិដ្ឋានសម្រាប់បងប្អូនដែរ គឺឲ្យបងប្អូនមានប្រាជ្ញា ឲ្យបងប្អូនស្គាល់ព្រះយេស៊ូយ៉ាងច្បាស់ ដើម្បីអាចកសាងព្រះសហគមន៍បាន។ សព្វថ្ងៃយើងរស់នៅក្នុងសេចក្តីសុខសាន្ត ប៉ុន្តែយើងដឹងថាជីវិតរបស់យើងមានការតស៊ូខ្លាំងណាស់ ហើយមរណសាក្សីពីដើមក៏លោកបានតស៊ូយ៉ាងខ្លាំងដែរ នេះជាមូលហេតុណែនាំឲ្យព្រះសហគមន៍នីមួយៗមានជីវិតដល់សព្វថ្ងៃ។ នៅប្រទេសវៀតណាម ប្រទេសកូរ៉េ ប្រទេសចិន ប្រទេសជប៉ុន ប្រទេសកម្ពុជាដែរ គឺនៅទ្វីបអាស៊ីយើង ជាទ្វីបនៃមរណសាក្សីដែលបានលះបង់ជីវិតដោយត្រូវគេកាត់ក គេសម្លាប់ គេបាញ់ គេដុត គេធ្វើបាប... ដើម្បីការពារ និង

ថៃរក្សាជំនឿ បន្តទុករហូតមកដល់សព្វថ្ងៃនេះ។

ប៉ុន្មានថ្ងៃនេះ យើងបានស្តាប់អត្ថបទគម្ពីរអេភេសូ ដែលសន្តៈប៉ូលបានប្រៀនប្រដៅណែនាំដល់គ្រីស្ត បរិស័ទយើង។ អត្ថបទនេះ ក៏បានណែនាំដល់បងប្អូននៅបឹងឈូក និងទួលក្រសាំង នៅថ្ងៃទី១នៃដំណើរ សួរសុខទុក្ខរបស់ខ្ញុំ និងបានណែនាំដល់បងប្អូននៅស្ពាង និងសំប៉ាននៅថ្ងៃទី២ និងថ្ងៃនេះបានណែនាំដល់ បងប្អូននៅកោះទាវ គឺសូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីឲ្យបងប្អូនមានប្រាជ្ញា និងដើម្បីឲ្យបងប្អូនស្គាល់ ព្រះគ្រីស្ត។ ថ្ងៃស្អែក មានកូនៗរបស់យើងនឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលណែនាំឲ្យមានប្រាជ្ញា និង ស្គាល់ព្រះបិតា។ ដូច្នេះសម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវអធិដ្ឋានសូមឲ្យយើងធ្វើតាមព្រះហឫទ័យ ព្រះជាម្ចាស់ និងឲ្យយើងចេះអធិដ្ឋានដូចសន្តីតេរេសា។ សូមឲ្យយើងអធិដ្ឋានជាប្រចាំ ដើម្បីជាប់ជាមួយ ព្រះយេស៊ូ។ ពេលយើងជាប់ជាមួយព្រះយេស៊ូនោះ យើងអាចកសាងព្រះសហគមន៍បាន ដោយសារ ព្រះយេស៊ូជាសិរសា។ ព្រះយេស៊ូណែនាំឲ្យយើងស្រឡាញ់ដូចព្រះអង្គ ណែនាំឲ្យយើងលើកលែងទោសដូច ព្រះអង្គ ណែនាំឲ្យយើងជួយដល់បងប្អូនឯទៀតៗ ឲ្យមានសេចក្តីសុខជានិច្ច ដូចសន្តៈប៉ូលមានប្រសាសន៍ ថា **"សូមឲ្យបងប្អូនបានទទួលសេចក្តីសុខសាន្ត និងសេចក្តីសង្ឃឹមជានិច្ចពីព្រះជាម្ចាស់"**។ ពេលណាយើង អធិដ្ឋានហើយយើងធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ នោះមានន័យថាយើងធ្វើតាមគំរូរបស់មរណសាក្សី ហើយ ដោយសារមរណសាក្សីបានធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ដោយបានអធិដ្ឋាន បានបម្រើបងប្អូន ក្នុងសេចក្តីស្រឡាញ់ជានិច្ច។ ដូច្នេះព្រះសហគមន៍របស់យើង អាចទៅជាព្រះសហគមន៍ដ៏វិសុទ្ធលុះត្រា តែយើងអធិដ្ឋាន យើងបម្រើ និងយើងស្រឡាញ់គ្នាទៅវិញទៅមក ជាពិសេសយើងនាំយកសេចក្តីស្រឡាញ់ ដែលយើងបានទទួលពីព្រះជាម្ចាស់ ទៅចែកដល់បងប្អូនឯទៀតៗ។ ប្រសិនបើព្រះសហគមន៍មិនទុក ព្រះយេស៊ូជាសិរសា ដើម្បីណែនាំយើងទេ នោះព្រះសហគមន៍របស់យើងអត់មានជីវិតទេ។

ថ្ងៃនេះយើងដឹងថាយើងជាព្រះកាយព្រះគ្រីស្ត យើងជាព្រះសហគមន៍ដែលចេះអធិដ្ឋាន យើងជា ព្រះសហគមន៍ ដែលចេះបម្រើ និងស្រឡាញ់បងប្អូនឯទៀតៗ និងយើងជាព្រះកាយព្រះគ្រីស្តពិតៗ។ យើង ដឹងថា យើងមានព្រះយេស៊ូដែលមានព្រះហឫទ័យប្រណីសន្តោសដល់យើង យើងជាប្រជារាស្ត្ររបស់ ព្រះជាម្ចាស់ដែលសុខចិត្តបូជាជីវិតដើម្បីព្រះសហគមន៍។ នៅខែធ្នូឆ្នាំ២០១៦នេះ ខាងមុខនេះ ប្រទេសឡាវ នឹងតែងតាំងមរណសាក្សី១៧រូបថែមទៀត។ ពួកគាត់បានបូជាជីវិតនៅសម័យកុម្មុយនីស្តពីឆ្នាំ១៩៧០ដល់ ឆ្នាំ១៩៧៥នៅប្រទេសឡាវ។

សូមបងប្អូនរួមគ្នាអធិដ្ឋាន ដើម្បីឲ្យយើងទៅជាមរណសាក្សីដោយសុខចិត្តលះបង់ ដោយអធិដ្ឋាន ដោយ បម្រើ និងដោយស្រឡាញ់ជានិច្ច។ អាម៉ែន។

# BÀI GIẢNG CỦA ĐỨC CHA OLIVIER
## Thăm mục vụ Koh Tieu
## Ngày 15/10/2016

**Anh chị em thân mến!**

**Trong bài đọc 1, trích thư Thánh Phao-lô Tông đồ gởi tín hữu Ê-phê-sô, Ngài viết: "Đức Giê-su là Đầu, Hội Thánh là Thân Thể của Người và chính Người đồng bản tính với Đức Chúa Cha". Bài đọc này giúp chúng ta hiểu rằng, chúng ta hãnh diện vì là thân thể của Đức Ki-tô, với Người là Đầu. Trong nhà thờ có ảnh của 117 Thánh Tử đạo Việt Nam. Khi nhìn thấy liền khiến ta liên tưởng ngay đến Đức Ki-tô là Đầu của Hội thánh, là thân thể của Người. Một Hội Thánh, với Dân Người, sẵn sàng hy sinh lợi ích cá nhân vì họ là 1 phần thân thể của Hội Thánh. Chi thể của Đức Ki-tô chính là mọi Ki-tô hữu, bao gồm cả các tu sĩ nam nữ, các linh mục, Giám mục, các vị thừa sai, … Trong số đó có cha Ste-phan Bê-na, hiện nay có xương của Ngài ở nhà thờ Bình Di. Ngài bị người ta bắt nhốt 3 ngày, rồi bị giết. Có cha Bu-nam bị người ta chặt đầu. Kẻ giết cha cũng chính là bạn thân của cha. Khi giết cha, người bạn này đã mâu thẫn trong lòng rất lớn, hắn đã uống rượu say và chém Ngài đến 7 lần mới đứt đầu. Qua những sự kiện này cho thấy, Giáo hội có Đức Giê-su, Đấng đã bị người ta ngược đãi, là đầu; và Dân Thiên Chúa đã hiến dâng mạng sống là Nhiệm Thể của Đức Ki-tô. Chúng ta là những tu sĩ nam nữ, Linh mục, giáo dân cũng là thân thể của Đức Ki-tô, với Ngài là Đầu dẫn dắt, soi sáng, ban ơn can đảm và đức tin vững mạnh cho chúng ta.**

**Thánh Phao-lô dã nguyện xin cùng Thiên Chúa, ban Chúa Thánh Thần để ban cho anh chị em ơn khôn ngoan, cho anh chị em nhận biết Thiên Chúa cách rõ ràng. Hôm nay, tôiđến dây cũng là để cầu nguyện cho anh chị em, xin cho anh chị em được ơn khôn ngoan để nhận biết Đức Giê-su cách rõ ràng hơn, từ đó, có thể xây dựng Hội thánh. Hiện nay chúng ta đang sống trong thời bình, nhưng anh chị em cũng biết là đời sống cần cố gắng rất nhiều, chính các Thánh tử đạo xưa cũng đã kiên trì rất lớn, nhờ đó mà đã đem lại sức sống cho mỗi giáo xứ, giáo họ. Ở Việt Nam, Hàn Quốc, Trung Quốc, Nhật Bản và cả Campuchia, hay Châu Á nói chung, là châu lục của các Thánh tử đạo, những người đã hy sinh mạng sống mình, bị người ta giết, chặt đầu, xử bắn, hỏa thiêu, hành hạ,…**

chỉ vì bảo vệ và gìn giữ đức tin cho được lưu truyền đến ngày nay. Mấy ngày nay, chúng ta được nghe thư của Thánh Phao-lô Tông đồ gởi giáo đoàn Ê-phê-sô, Ngài đã dạy bảo, hướng dẫn cho Ki-tô hữu chúng ta. Bức thư này cũng đã hướng dẫn cho anh chị em ở Boeung Chhuk và Tual Crsang trong ngày đầu tiên của chuyến viếng thăm của tôi, hướng dẫn anh chị em ở Saang và Tam Bản trong ngày thứ 2, và hôm nay là anh chị em ở đây. Xin Chúa Thánh Thần ngự đến, ban cho anh chị em thần trí khôn ngoan để anh chị em được nhận biết Đức Ki-tô. Ngày mai, sẽ có 1 số con em của chúng ta được đón nhận Chúa Thánh Thần, Đấng ban ơn khôn ngoan và dẫn họ đến với Đức Chúa Cha. Vì vậy, đối với người Ki-tô hữu, chúng ta phải cầu nguyện, xin cho được vâng theo Thánh ý Chúa và cầu nguyện như Thánh Tê-rê-sa. Hãy cầu nguyện luôn để được kết hợp với Đức Giê-su. Khi chúng ta kết hợp với Đức Giê-su, chúng ta sẽ dễ dàng xây dựng Hội Thánh vì Ngài là đầu. Ngài sẽ hướng dẫn để ta biết yêu như Ngài, tha thứ như Ngài, giúp đỡ anh chị em bên cạnh được bình an như Thánh Phao-lô đã nói: "Xin cho anh chị em mãi được ơn bình an và hy vọng từ Thiên Chúa". Khi nào chúng ta cầu nguyện và làm theo Thánh ý Chúa, là chúng ta đang noi theo gương của các Thánh tử đạo, vì các Ngài luôn vâng theo Thánh ý Chúa nhờ đời sống cầu nguyện và phục vụ mọi người trong tình yêu. Vậy nên, Giáo hội của chúng ta có trở nên Thánh thiện hay không chỉ khi nào chúng ta biết cầu nguyện, phục vụ và yêu thương nhau. Đặc biệt, chúng ta phải biết đem tình yêu mà chúng ta nhận được từ Thiên Chúa chia sẻ với người khác. Nếu Giáo hội không để cho Đức Ki-tô là đầu dẫn dắt thì sẽ không có sự sống.

Hôm nay, anh chị em biết rằng mình là thân thể của Đức Ki-tô. Chúng ta là 1 Giáo hội biết cầu nguyện, biết phục vụ, yêu thương người khác và là Nhiệm Thể đích thực của Đức Ki-tô. Chúng ta cũng biết rằng, nhờ hồng ân của Đức Giê-su, chúng ta trở thành Dân Riêng của Thiên Chúa, sẵn sàng hiến dâng mạng sống vì Giáo hội. Tháng 12 năm 2016 tới đây, nước Lào sẽ phong thánh cho 12 vị tử đạo, họ đã hy sinh tính mạng trong thời Cộng sản từ năm 1970 – 1975 ở bên Lào.

Xin anh chị em hãy hiệp ý cầu nguyện để chúng ta cũng trở thành những vị tử đạo bởi luôn cầu nguyện, phục vụ và yêu thương. Amen.

# ព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ




សកម្មភាពលោកអភិបាល ទស្សនកិច្ចនៅព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ





# ប្រវត្តិព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ

ព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ បានកសាងតាំងពីយូរឆ្នាំមកហើយ។ ពេលសង្គ្រាមកើតឡើង ព្រះសហគមន៍នេះបានបិទទ្វារមួយរយៈ។ ក្នុងឆ្នាំ១៩៧៩ គ្រីស្តបរិស័ទដែលភៀសខ្លួនទៅប្រទេសវៀតណាម បានវិលត្រលប់មកកម្ពុជាវិញ ហើយបានសាងសងព្រះវិហារធ្វើពីឈើតូចមួយ ដើម្បីជួបជុំគ្នាអធិដ្ឋាននៅថ្ងៃអាទិត្យ។ រហូតដល់ឆ្នាំ២០០៨ ព្រះសហគមន៍នេះបានកសាងព្រះវិហារថ្មី ដែលធ្វើពិធីបុណ្យឆ្លង និងប្រសិទ្ធិពរដោយលោកអភិបាល អេមីល ដេតម្ប។

ព្រះសហគមន៍ជ្រៃធំ មានគ្រីស្តបរិស័ទប្រមាណជាង៣០០គ្រួសារ ស្មើនឹង១៤២០នាក់។

ក្រុមផ្សេងៗ៖ ក្រុមយុវជន ក្រុមចម្រៀង ក្រុមកាយឫទ្ធិ ក្រុមបេះដូងព្រះយេស៊ូ ក្រុម Legio ម៉ារី ក្រុមសន្តីតេរេសា គណៈកម្មការសង្គហៈ គណៈកម្មការអប់រំជំនឿ គណៈកម្មការពិធីបុណ្យ។

សាលារៀន៖ មានសាលាមតេយ្យ និងសាលាបឋមសិក្សាពីថ្នាក់ទី១ដល់ទី៣។















## សកម្មភាពលោកអភិបាល ទស្សនកិច្ចនៅព្រះសហគមន៍សន្តយ៉ូសែប ជ្រៃធំ



# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាទស្សនកិច្ចនៅព្រែជធំ
# ថ្ងៃទី១៦ តុលា ២០១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាថ្ងៃចុងក្រោយនៃដំណើរចុះសួរសុខទុក្ខរបស់ខ្ញុំ ក្នុងមណ្ឌលសកម្មភាពទន្លេបាសាក់។ ក្រោយពីខ្ញុំបានឃើញ បានឮ ខ្ញុំសូមជូនសេចក្ដីខ្លះដល់បងប្អូនដើម្បីឲ្យបងប្អូនរីកចម្រើនថែមទៀតក្នុងជំនឿក្នុងការរស់នៅជាព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពបាសាក់យើង។ ក្នុងគម្ពីរដំណឹងល្អថ្ងៃនេះ យើងបានស្ដាប់ឮសំណួររបស់ព្រះយេស៊ូថា ***"នៅពេលបុត្រមនុស្សមកដល់ តើលោកឃើញមនុស្សមានជំនឿនៅលើផែនដីនេះឬទេ?"***។ ព្រះយេស៊ូក៏សួរសំណួរនេះដល់យើងដែរ **តើពេលព្រះអង្គយាងមកដល់ ព្រះអង្គឃើញបងប្អូននៃមណ្ឌលសកម្មភាពបាសាក់ឬទេ?** នេះជាអ្វីដ៏សំខាន់នៃជំនឿរបស់យើងលើព្រះជាម្ចាស់ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

មុនអ្វីទាំងអស់ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ចំពោះអ្វីដែលខ្ញុំបានឃើញ អ្វីដែលខ្ញុំបានឮក្នុងដំណើរចុះសួរសុខទុក្ខបងប្អូនបួនថ្ងៃកន្លងមកនេះ។

ទី១ ខ្ញុំបានឃើញ ខ្ញុំបានឮអំពីជំនឿរបស់បងប្អូននៅមណ្ឌលសកម្មភាពទន្លេបាសាក់។ ខ្ញុំបានឃើញថាបងប្អូនយកចិត្តទុកដាក់ក្នុងការអធិដ្ឋាន យកចិត្តទុកដាក់ចូលអភិបូជា យកចិត្តទុកដាក់ក្នុងសកម្មភាព ក្រុមផ្សេងៗ មានក្រុមLegio ក្រុមព្រះបេះដូងព្រះយេស៊ូ...។ នេះខ្ញុំយល់ថា បងប្អូននៅមណ្ឌលសកម្មភាពទន្លេ-បាសាក់មានជំនឿលើព្រះយេស៊ូពិតមែន។

ទី២ ខ្ញុំបានឃើញពីរបៀបដែលបងប្អូនតស៊ូ។ មណ្ឌលសកម្មភាពបាសាក់ជាមណ្ឌលសកម្មភាពចាស់របស់ភូមិភាគភ្នំពេញ ដែលមានតាំងពីមុនសម័យប៉ុលពតទៅទៀត។ មានបងប្អូនគ្រីស្ដបរិស័ទពីដើមជាច្រើនបានត្រឡប់មកពីវៀតណាមវិញនៅឆ្នាំ១៩៨០។ នៅក្នុងគ្រាដ៏លំបាកនោះ បងប្អូនបានតស៊ូដើម្បីកសាងព្រះសហគមន៍បន្តិចម្ដងៗឡើងវិញ។ បងប្អូនបានប្រាប់ខ្ញុំថា ពេលត្រឡប់មកដល់វិញភ្លាម កាលនោះបងប្អូនដូចជាស្ថិតនៅក្នុងព្រៃមិនដឹងអីសោះ ចង់ភ្លេចជំនឿអស់ហើយដោយសារតែទុក្ខវេទនាច្រើនពេក។ ប៉ុន្តែបន្តិចម្ដងៗ បងប្អូនបានយកចិត្តទុកដាក់ចេញពីព្រៃនៃភាពងងឹតនោះ រកឃើញជំនឿឡើងវិញ និងរួមគ្នាកសាងព្រះសហគមន៍តាមកន្លែងនីមួយៗដូចយើងបានឃើញសព្វថ្ងៃ គឺជាព្រះសហគមន៍ដែលមានជីវិត។ ខ្ញុំបានឃើញពីការតស៊ូរបស់បងប្អូនក្នុងការរស់នៅប្រចាំថ្ងៃនៅក្នុងទុក្ខលំបាកដោយសារបងប្អូនមិនរស់នៅលើទឹកដីរបស់ជនជាតិខ្លួន។ បងប្អូនមានបញ្ហាជាមួយឯកសាររស់នៅជាមួយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ...។ ខ្ញុំបានឃើញពីជីវភាពក្រីក្ររបស់បងប្អូន ពីមុខរបររកស៊ី ពីការងារតូចតាចដែលបងប្អូនធ្វើដើម្បីចិញ្ចឹមជីវិតក្រុមគ្រួសារផ្ទាល់ពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំបានឃើញពីការតស៊ូក្នុងការរស់នៅរបស់បងប្អូននៅ

តាមទីកន្លែងផ្សេងៗ។

ទី៣ ខ្ញុំបានឃើញពីអំណរសប្បាយរបស់បងប្អូន និងកម្លាំងដែលបងប្អូនមាន។ នៅតាមកន្លែងនីមួយៗ ខ្ញុំបានឃើញពីរបៀបដែលបងប្អូនស្វាគមន៍គ្នា របៀបដែលបងប្អូនប្រមូលគ្នា មានកូនក្មេង មានយុវជន មានមនុស្សចាស់ៗ ដែលមើលទៅដូចជាមានកម្លាំងដ៏បរិបូណ៌។ ថ្ងៃនេះខ្ញុំបានឃើញថែមទៀតពីកម្លាំងរបស់បងប្អូន។ យប់មិញបងប្អូនបានអធិដ្ឋានពេញមួយយប់ ហើយព្រឹកនេះបងប្អូននៅតែមានកម្លាំង និងមានអំណរសប្បាយថែមទៀតនេះជាអំណោយទានមួយពិសេសពីព្រះជាម្ចាស់ ទោះបីការរស់នៅរបស់បងប្អូនមានទុក្ខវេទនាប៉ុន្តែបងប្អូននៅតែមានអំណរសប្បាយជានិច្ច។

ទី៤ ខ្ញុំបានឃើញនៅតាមកន្លែងនីមួយៗ ពីរបៀបដែលបងប្អូនរៀបចំព្រះសហគមន៍ គឺបងប្អូនយកចិត្តទុកដាក់ចាត់ចែងការងារបានយ៉ាងច្បាស់លាស់ជាពិសេសតាមរយៈគណៈកម្មការ តាមរយៈក្រុមនីមួយៗ ដូចជាក្រុមLegio ក្រុមព្រះបេះដូងព្រះយេស៊ូ ក្រុមកាយឫទ្ធិ ឬក្រុមយុវជនជាដើម ។ពេលខ្ញុំឃើញដូចនេះ ខ្ញុំស្ងើចសរសើរយ៉ាងខ្លាំង និងខ្ញុំអរព្រះគុណព្រះជាម្ចាស់ថែមទៀត។

ទី៥ ខ្ញុំបានឃើញប៉ុន្មានកន្លែង គឺបងប្អូនខិតខំយកចិត្តទុកដាក់កសាងសន្តិភាពសង្គម។ ខ្ញុំបានឮជាពិសេសនៅទួលក្រសាំងនៅសំប៉ាន បងប្អូនបានបង្កើតទំនាក់ទំនងរវាងសហគមន៍ខ្មែរនិងវៀតណាមឲ្យទៅជាគ្រួសារតែមួយ តាមរយៈការឧបត្ថម្ភការសិក្សាដល់ក្មេងៗ តាមរយៈការជូនអំណោយសង្គ្រោះ ការជួយអ្នកជំងឺជាដើម។ នេះជាសញ្ញាសម្គាល់ថាពិតមែនបងប្អូនជាអ្នកកសាងសុខសន្តិភាពក្នុងសង្គមដោយបងប្អូនចេះស្រឡាញ់គ្នា និងបម្រើគ្នាទៅវិញទៅមក។

ទី៦ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដោយខ្ញុំបានឃើញអ្នកគង្វាលដ៏សប្បុរស គឺជាលោកឪពុកទីន។ លោកឪពុកទីនបានជួយណែនាំបងប្អូនតាំងពីយូរហើយ លោកឪពុកបានទទួលទាំងមណ្ឌលសកម្មភាពបាសាក់ទាំងមណ្ឌលសកម្មភាពមេគង្គ ដែលមានជិត២០ព្រះសហគមន៍។ ក្រោយមកនៅសល់១២ ហើយឥឡូវនៅសល់៦។ ដូច្នេះខ្ញុំសូមអរគុណជាច្រើនដល់លោកឪពុក និងអរគុណបងប្រុសបងស្រីដែលបានចែកការងារគ្នាក្នុងកិច្ចការបម្រើបងប្អូនក្នុងសេចក្ដីស្រឡាញ់ ឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍របស់ព្រះគ្រីស្ត។

សំណួរចំពោះយើង ***"តើពេលព្រះយេស៊ូយាងមកដល់ ព្រះអង្គបានឃើញអ្នកមានជំនឿនៃមណ្ឌលសកម្មភាពទន្លេបាសាក់ឬទេ?"***។ ធ្វើដូចម្ដេចដើម្បីថែរក្សាជំនឿនេះ? សន្តះប៉ូលឆ្លើយថា ***"ចូរប្រកាសព្រះបន្ទូល"*** មានន័យថា និយាយហើយនិយាយទៀតឲ្យតែមានឱកាស ទោះបីឱកាសនោះល្អក្តី មិនល្អក្តី ឬត្រូវស្តីបន្ទោស ត្រូវដាស់តឿន ឬត្រូវមានចិត្តអត់ធ្មត់គ្រប់បែបយ៉ាង។ ដោយហេតុនេះហើយខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់នៅក្នុងមណ្ឌលសកម្មភាពបាសាក់សម្លឹងមើលព្រះយេស៊ូ និងខ្ញុំមានប្រាំបីចំណុចជូនដល់បងប្អូនដើម្បីឲ្យបងប្អូនរីកចម្រើននៅក្នុងជំនឿ។

ទី១ សូមបងប្អូនធ្វើជាធ្លុងតែមួយជាមួយព្រះយេស៊ូ ដោយយកចិត្តទុកដាក់អធិដ្ឋាន ថ្វាយអភិបូជា និងស្តាប់ព្រះបន្ទូលជានិច្ច។ កិច្ចការទាំងបីនេះ ជាអាទិភាពទី១ ក្នុងការរស់នៅរបស់បងប្អូន ដើម្បីឲ្យបងប្អូនរក្សា

ជំនឿបាន។ មណ្ឌលសកម្មភាពបាសាក់យើងមានលោកបូជាចារ្យតិចណាស់ដើម្បីថ្វាយអភិបូជា មានតែលោកឪពុកទីន លោកឪពុកប៊ិប់ លោកឪពុក ហ្វ្រង់ស៊ីស្កូ និងលោកខ្លះទៀតប៉ុណ្ណោះ។ ពេលអត់មានអភិបូជាប្រចាំ នោះយើងមានបងប្រុសបងស្រីដែលជួយណែនាំ។ សូមឲ្យបងប្អូនយកចិត្តទុកដាក់អធិដ្ឋានតាមម៉ោងតាមក្រុម Legio ព្រះបេះដូងព្រះយេស៊ូ ក្រុមកូនក្មេង ដើម្បីថែរក្សាជំនឿរបស់យើង។

ទី២ ខ្ញុំសូមអញ្ជើញបងប្អូនឲ្យយកចិត្តទុកដាក់ចំពោះការអប់រំជំនឿ គឺអប់រំជំនឿសម្រាប់កូនក្មេង សម្រាប់យុវជន និងសម្រាប់មនុស្សពេញវ័យដែរ ដ្បិតថាយើងត្រូវតែទទួលការអប់រំថែមទៀត និងថែមទៀត។ ខ្ញុំសូមឲ្យបងប្រុស និងបងស្រីយកចិត្តទុកដាក់ឲ្យការអប់រំជំនឿនោះបានច្បាស់លាស់ដើម្បីឲ្យកូនៗរបស់យើងយល់ពីជំនឿរបស់គេ។ សូមឲ្យមានអប់រំជំនឿទាំងពីរភាសា ទាំងភាសាវៀតណាម និងភាសាខ្មែរ។ ឆ្នាំមុនខ្ញុំតែងតាំងបងស្រីម៉ាថា និងបងស្រីលីភី ឲ្យជួយបកប្រែសៀវភៅអប់រំជំនឿ មានមួយទំព័រជាភាសាខ្មែរ និងមួយទំព័រទៀតជាភាសាវៀតណាម ឲ្យក្មេងៗអាចស្ដាប់បានទាំងពីរភាសា។

ទី៣ ខ្ញុំសូមឲ្យក្រុមនីមួយៗ មានក្រុមគណៈកម្មការ ក្រុមLegio ក្រុមព្រះបេះដូងព្រះយេស៊ូ យកចិត្តទុកដាក់ទទួលខុសត្រូវយ៉ាងច្បាស់លាស់ចំពោះតួនាទីរបស់ខ្លួន។ គណៈកម្មការបានទទួលបេសកកម្មពីព្រះសហគមន៍ ពីគ្រីស្ដបរិស័ទដើម្បីបម្រើព្រះសហគមន៍។ បងប្អូនដែលមានឈ្មោះនៅក្នុងគណៈកម្មការត្រូវយកចិត្តទុកដាក់ចំពោះតួនាទីរបស់ខ្លួន។ ម្សិលមិញខ្ញុំបានប្រជុំគណៈកម្មការជាផ្លូវការនៅទីនេះ ប៉ុន្តែសមាជិក៨នាក់ មិនបានមក។ ចំពោះក្រុមLegio ក្រុមព្រះបេះដូងព្រះយេស៊ូ ក៏ដូចគ្នាដែរ មិនត្រូវមានតែឈ្មោះពេលលោកអភិបាលមកនោះទេ។ អាទិត្យក្រោយខ្ញុំធ្វើមហាសន្និបាតក្រុមព្រះបេះដូងព្រះយេស៊ូសូមឲ្យអ្នកដែលមានឈ្មោះមកទាំងអស់គ្នា។ រាល់អាទិត្យសូមឲ្យបងប្អូនចូលរួមក្នុងសកម្មភាពរបស់ក្រុមតាមការកំណត់។ នេះជាតួនាទីរបស់បងប្អូនដែលជាអ្នកបម្រើព្រះសហគមន៍។

ទី៤ ឲ្យយើងយកចិត្តទុកដាក់សហការគ្នាយ៉ាងជិតស្និទ្ធនៅក្នុងព្រះសហគមន៍។ ទីមួយសហការគ្នារវាងលោកបូជាចារ្យ បងប្រុសបងស្រី និងគណៈកម្មការ ដោយចែកយោបល់គ្នាជាប្រចាំអំពីការកសាងព្រះសហ-គមន៍។ សូមបងប្រុសបងស្រីទាំងអស់មកទីនេះ មួយខែម្ដងប្រជុំជាមួយលោកឪពុកដើម្បីចែកព័ត៌មានគ្នាយ៉ាងច្បាស់លាស់ និងចែកការងារគ្នាក្នុងមណ្ឌលសកម្មភាពយ៉ាងច្បាស់លាស់ដែរ។ បងប្រុសបងស្រីមានតួនាទីជាអ្នកដឹកនាំដោយរួមជាមួយលោកបូជាចារ្យ (លោកឪពុក) ដោយមិនឯករាជ្យតាមកន្លែងនីមួយៗទេ។ លោកឪពុកជាអ្នកថែរក្សាឯកភាពជាធ្លុងមួយក្នុងមណ្ឌលសកម្មភាព។ ទីពីរក្នុងការសហការគ្នានេះមណ្ឌលសកម្មភាពទាំងមូលក៏ត្រូវសហការបន្តជាមួយភូមិភាគភ្នំពេញយ៉ាងជិតស្និទ្ធបំផុតដែរ មានន័យថាជាមួយលោកអភិបាលយ៉ាងជិតស្និទ្ធ ដ្បិតមណ្ឌលសកម្មភាពនេះស្ថិតនៅក្នុងភូមិភាគភ្នំពេញ មិនមែនសាខាពីព្រះសហគមន៍នៅវៀតណាមទេ។

ទី៥ ខ្ញុំអញ្ជើញបងប្អូនគិត និងគិតទៀតពីអនាគតកូនៗ ជាពិសេសបងប្អូនជាឪពុកម្ដាយ ជាតាយាយដែលមានកូនចៅត្រូវទទួលការអប់រំ។ នៅតាមកន្លែងនីមួយៗ សូមឲ្យមានការសិក្សាយ៉ាងច្បាស់លាស់តាមអ្វីដែលយើងបានរៀបចំមានដូចជា៖ មត្តេយ្យសិក្សា ថ្នាក់ទី១ និងថ្នាក់ទី២។ សព្វថ្ងៃពិភពលោកយើងចូលក្នុង

សតវត្សរ៍ទី២១ហើយ ដូច្នេះត្រូវឲ្យកូនៗរបស់យើងចូលនៅក្នុងសតវត្សរ៍នេះដែរ ដោយឲ្យគេបានទទួលការសិក្សាអប់រំ ដែលជាផ្លូវតែមួយជួយឲ្យកូនចៅរបស់យើងមានអនាគតល្អ។ កុំទុកកូនចៅឲ្យជួយធ្វើការរបស់ខ្លួននៅតាមផ្ទះ។ ខ្ញុំបានឃើញនៅកន្លែងខ្លះ មានកុមារៗអាយុ១៣-១៤ឆ្នាំ នៅធ្វើកិច្ចការតាមផ្ទះ គេរើសអេតចាយ គេធ្វើប្រហិតត្រីធ្វើត្រីងៀត...។ ទោះលំបាកយ៉ាងម្តេចក្តី សូមបងប្អូនគិតអំពីការសិក្សារបស់កូនចៅប្រសិនបើគេមានការសិក្សា នោះគេនឹងមានអនាគតល្អ។ នៅតាមភូមិខ្មែរក៏ដូចគ្នាដែរ សព្វថ្ងៃគេឲ្យកូនៗចោលការសិក្សាទៅធ្វើការនៅរោងចក្រដោយគិតថាបានលុយភ្លាមៗ ប៉ុន្តែរោងចក្រអត់ផ្តល់អនាគតវែងឆ្ងាយទេ។ ដូច្នេះយើងជាគ្រីស្តបរិស័ទត្រូវមានប្រាជ្ញាឈ្លៀសវៃ។ កូនចៅទាំងអស់នៅទីនេះគេចង់មានអនាគតភ្លឺស្វាង គេមិនចង់រស់នៅដោយវេទនាទេ។ ដូច្នេះសូមបងប្អូនជាឪពុកម្តាយ ជាយាយជាតាភ្ញាក់ស្មារតីទៅ! និងសូមជួយជំរុញឲ្យកូនចៅៗរបស់ខ្លួននៅទីនេះទៅរៀនសូត្រ ដើម្បីទទួលអនាគតល្អ។

ទី៦ ឲ្យយើងទៅជាសញ្ញានៃការលើកលែងទោសដែលមកពីព្រះជាម្ចាស់នៅក្នុងព្រះសហគមន៍ នៅក្នុងគ្រួសារ និងនៅក្នុងសង្គម។ ខ្ញុំជឿថានៅក្នុងព្រះសហគមន៍ជួនកាលយើងឈ្លោះគ្នា ជួនកាលគណៈកម្មការអន់ចិត្តគ្នា... ប៉ុន្តែយើងត្រូវតែសម្រុះសម្រួលគ្នាដោយសារព្រះអម្ចាស់យេស៊ូយាងមកដើម្បីលើកលែងទោសឲ្យយើង ហេតុនេះហើយយើងត្រូវតែលើកលែងទោសឲ្យគ្នាទៅវិញទៅមកដែរ។ នៅក្នុងគ្រួសារក៏ដូចគ្នាដែរ ជួនកាលយើងមិននិយាយរកគ្នា ឈ្លោះគ្នារវាងឪពុកម្តាយនិងកូន រវាងប្តីនិងប្រពន្ធ ... ប៉ុន្តែព្រះជាម្ចាស់យាងមកឲ្យយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។

ទី៧ ឲ្យយើងបន្តយកចិត្តទុកដាក់សម្តែងមេត្តាករុណាជានិច្ច។ នៅក្លោងទ្វារព្រះវិហារ មានសរសេរជាភាសាខ្មែរថា ***"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"*** ហេតុដូច្នេះហើយ ជីវិតយើងជាគ្រីស្តបរិស័ទ គឺត្រូវតែស្រឡាញ់ និងចែកសេចក្តីស្រឡាញ់នោះដល់បងប្អូននៅក្នុងព្រះសហគមន៍របស់យើង ប៉ុន្តែខ្ញុំសូមរំឭកថា សូមបន្តចែកសេចក្តីស្រឡាញ់នោះដល់បងប្អូនទាំងអស់ ដោយសារក្នុងមណ្ឌលសកម្មភាពបាសាក់ យើងមានព្រះសហ-គមន៍ដែលដុះឡើងថ្មី នៅតាមភូមិនានាចំនួន៦កន្លែងទៀត។ ដូច្នេះ តើយើងត្រូវធ្វើដូចម្តេច ដើម្បីប្រកាសដំណឹងល្អតាមរយៈមេត្តាករុណាដល់បងប្អូនឯទៀតៗ ជាពិសេសបងប្អូនខ្មែរដែលជាម្ចាស់ទឹកដីនៅទីនេះ។ កន្លងមក បងប្អូនបានសម្តែងមេត្តាករុណាច្រើនហើយ ប៉ុន្តែកិច្ចការមេត្តាករុណានេះមិនដែលល្មមទេ ដូច្នេះ ខ្ញុំសូមអញ្ជើញបងប្អូនអនុវត្តថែមទៀតនិងថែមទៀត ដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់បានទៅដល់គ្រប់ទីកន្លែងដែលយើងរស់នៅ និងចេញពីព្រះសហគមន៍យើងទៅកន្លែងផ្សេងៗទៀត។

ទី៨ ចំណុចចុងក្រោយបំផុត ឲ្យយើងទាំងអស់គ្នាជាព្រះសហគមន៍នៅក្នុងមណ្ឌលសកម្មភាពបាសាក់ទៅជាសញ្ញានៃសុខសន្តិភាពពិតៗ ក្នុងសង្គមដែលកំពុងខ្វះសន្តិភាព។ ជាពិសេសនៅពេលនេះខ្ញុំសូមឲ្យយុវជនយុវនារីដែលទទួលអគ្គសញ្ញាលាបថ្ងាសនឹកឃើញជានិច្ចថា ព្រះវិញ្ញាណដ៏វិសុទ្ធជាសុខសន្តិភាពនៃព្រះជាម្ចាស់ដែលយាងមក និងសូមឲ្យចែកសុខសន្តិភាពនេះតាមការរស់នៅប្រចាំថ្ងៃសមដូចសន្តៈប៉ូលបានមានប្រសាសន៍ថា ***"យើងបង្រៀនគេដោយចិត្តអត់ធ្មត់គ្រប់យ៉ាង ដូច្នេះយើងត្រូវតែតស៊ូនៅក្នុងចិត្តអត់ធ្មត់ដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់"***។

បងប្អូនជាទីស្រឡាញ់!ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះសហគមន៍មណ្ឌលសកម្មភាពបាសាក់ដ៏ស្រស់ស្អាត។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ចំពោះលោកឪពុកទីន ចំពោះបងប្រុសបងស្រី និងចំពោះបងប្អូនទាំងអស់ដែលយកចិត្តទុកដាក់ស្រឡាញ់ បម្រើ និងអធិដ្ឋាន។ ខ្ញុំសូមអធិដ្ឋានសម្រាប់បងប្អូនជានិច្ច និងសូមបងប្អូនអធិដ្ឋានសម្រាប់ព្រះសហគមន៍យើងវិញផង។ សូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើងខ្ញុំ ឲ្យយើងខ្ញុំកសាងព្រះសហគមន៍។

ជ័យយោព្រះសហគមន៍មណ្ឌលសកម្មភាពបាសាក់! ។ អាម៉ែន។







**អគ្គសញ្ញាណលាបថ្ងាសរបស់បេក្ខជនក្នុងមណ្ឌលបាសាក់**





**BÀI GIẢNG CỦA ĐỨC CHA OLIVIER**

**Thăm mục vụ Bình Di**

**Ngày 16/10/2016**

**Anh chị em thân mến!**

**Hôm nay là ngày cuối cùng trong chuyến viếng thăm mục vụ của tôi đến Giáo hạt Basac. Sau những quan sát và lắng nghe, tôi xin gởi đến anh chị em đôi điều, để anh chị em được lớn mạnh thêm nữa trong đức tin và trong đời sống đạo. Bài Phúc âm hôm nay chúng ta được nghe Đức Giê-su hỏi rằng: "Khi Con Người ngự đến, liệu có còn niềm tin trên mặt đất không?". Đây cũng chính là câu hỏi Người dành cho chúng ta: khi Người ngự đến có còn thấy đức tin ở Giáo hạt Basac không? Đây là điều hết sức quan trọng trong đức tin của chúng ta vào Thiên Chúa là Cha và Con và Thánh Thần.**

**Trước hết, tôi xin tạ ơn Thiên Chúa về tất cả những gì tôi được thấy và được nghe trong suốt cuộc hành trình viếng thăm 4 ngày qua.**

**Thứ nhất: tôi đã thấy và nghe về đức tin của anh chị em ở Giáo hạt Basac này. Tôi đã thấy anh chị em chú tâm đến việc cầu nguyện, tham dự Thánh lễ, hoạt động trong các đoàn thể: có hội Legio, Gia đình phạt tạ Thánh Tâm Chúa Giê-su,…Tôi hiểu rằng anh chị em ở hạt Basac này có đức tin chân thật.**

**Thứ hai: tôi thấy cách mà anh chị em cố gắng. Hạt Basac là 1 hạt lâu đời, có từ trước thời Pol Pot trong giáo phận Phnompenh. Có rất nhiều giáo dân trước đây đã trở lại từ Việt Nam khoảng năm 1980. Trong thờ điểm vô cùng khó khăn đó, anh chị em đã cố gắng dần xây dựng trở lại các họ đạo. Anh chị em đã kể với tôi rằng, khi mới trở lại, anh chị em như đi giữa đám rừng, hoàn toàn vô định, dường như muốn quên mất đức tin vì quá khó khăn. Nhưng dần dần, anh chị em đã chủ tâm bước ra khỏi cánh rừng tối tăm đó, tìm lại đức tin, cùng nhau xây dựng nên các họ đạo có sức sống như ngày nay. Tôi nhìn thấy sự phấn đấu của anh chị em trong đời sống hằng ngày với hoàn cảnh sống khó khăn vì sống ở một nơi mà không phải là quê mẹ của mình. Anh chị em gặp nhiều vấn đề về giấy tờ, chứng minh, quốc tịch,… Tôi đã thấy đời sống khó khăn của anh chị em trên phương diện nghề nghiệp, những nghề nhỏ nhoi mà anh chị em làm để nuôi sống gia đình hằng ngày.**

**Thứ ba:** tôi đã thấy niềm vui và sức mạnh của anh chị em. Tại mỗi nơi, tôi đã thấy cách mà anh chị em - gồm trẻ em, giới trẻ, người già - chào đón, xum họp với nhau một cách rất có sức sống và mạnh mẽ. Hôm nay tôi lại được thấy thêm về sức mạnh của anh chị em. Anh chị em đã cầu nguyện suốt đêm qua, sáng nay tôi lại thấy sức sống và niềm vui bừng sáng trên khuôn mặt anh chị em. Đây là một hồng ân đặc biệt vì dẫu anh chị em gặp nhiều khó khăn, đau khổ, nhưng anh chị em vẫn mãi có một niềm vui.

**Thứ tư:** tạimỗi nơi, tôi đã thấy cách anh chị em tổ chức họ đạo. Anh chị em quan tâm đến việc sắp xếp công việc hết sức rõ ràng, qua Ban Hành Giáo, các hội đoàn như Legio, Hội Thánh Tâm, Hướng đạo, giới trẻ, v.v… Khi được thấy những điều này, tôi nhiệt liệt khen ngợi anh chị em và tạ ơn Thiên Chúa thêm nữa.

**Thứ năm:** tôi đã được thấy ở nhiều nơi anh chị em đã cố gắng tạo dựng sự hòa hợp cộng đồng. Đặc biệt, tôi đã nghe ở Tual Crsang, Tam Bản, anh chị em đã gây dựng mối quan hệ tốt giữa cộng đồng người Việt và Khmer, như 1 đại gia đình, qua các hoạt động như trợ cấp học tập cho trẻ em, viện trợ thiên tai, giúp đỡ người bệnh. Đây chính là dấu hiệu chứng tỏ rằng đích thật anh chị em đang xây dựng hòa bình trong xã hội thông qua việc yêu thương và phục vụ lẫn nhau.

**Thứ sáu:** tôi xin tạ ơn Thiên Chúa vì tôi được thấy vị chủ chăn nhân lành của anh chị em là Cha Tính. Cha đã dìu dắt, hướng dẫn anh chị em từ nhiều năm nay, kể từ khi cha phụ trách cả hạt Basac lẫn Mekong, với gần 20 giáo xứ, rồi sau còn 12 và hiện nay là 6. Vì vậy tôi cám ơn Cha rất nhiều.Và cũng xin cảm ơn quý thầy, quý sơ đã chia sẻ công việc phục vụ anh chị em trong tình yêu, khiến Giáo hội của chúng ta trở thành Giáo hội của Đức Ki-tô.

**Câu hỏi dành cho chúng ta là:** "Liệu khi Đức Giê-su ngự đến có còn thấy đức tin ở hạt Basac không?". Vậy, để gìn giữ đức tin này, Thánh Phao-lô trả lời: "Hãy rao giảng Tin Mừng", nghĩa là phải nói đi nói lại ngay khi có cơ hội, dù cơ hội có thuận lợi hay không, hoặc lên án, nhắc nhở, hoặc nhún nhường mọi bề. Chính vì thế, tôi mời gọi tất cả anh chị em trong hạt Basac, hãy nhìn lên Đức Giê-su. Tôi có 8 điểm xin gởi đến anh chị em để anh chị em được lớn

mạnh thêm nữa trong đức tin.

Thứ nhất: anh chị em hãy nên một với Đức Giê-su. Hãy chú tâm đến việc cầu nguyện, dâng Thánh lễ và luôn lắng nghe Lời Chúa. Cả 3 việc này là ưu tiên hàng đầu để anh chị em có thể gìn giữ đức tin trong đời sống của mình. Hạt Basac có rất ít Linh Mục dâng Thánh lễ, chỉ có Cha Tính, Cha Bob, Cha Phan-xi-cô và một vài cha nữa. Khi không có Linh mục chịu trách nhiệm trực tiếp, chúng ta có quý thầy, quý sơ giúp hướng dẫn. Xin anh chị em siêng năng cầu nguyện theo giờ, theo nhóm như Legio, Thánh Tâm, Thiếu nhi, v,v… để gìn giữ đức tin của mình.

Thứ hai: tôi mời gọi anh chị em hãy để tâm đến việc dạy Giáo lý cho trẻ em, thanh niên và cả người lớn, vì chúng ta cần phải học, học nữa và học mãi. Xin quý thầy, quý sơ quan tâm việc dạy giáo lý để con em của chúng ta hiểu về đức tin của mình. Xin dạy cho các em bằng cả 2 ngôn ngữ, cả tiếng Việt và Khmer. Năm ngoái, tôi đã đề cử sơ Mát-ta và sơ Li-Phi giúp dịch sách giáo lý để có 1 trang tiếng Việt và 1 trang tiếng Khmer, để các em có thể hiểu được cả 2 ngôn ngữ.

Thứ ba: tôi xin mỗi ban ngành đoàn thể như: Ban Hành Giáo, Hội Legio, Hội Thánh Tâm, có ý thức trách nhiệm rõ ràng về vai trò của mình. Ban Hành Giáo nhận nghĩa vụ từ Giáo xứ, từ giáo dân để phục vụ giáo xứ, anh chị em nào nằm trong danh sách Ban Hành Giáo hãy ý thức về vai trò của mình. Hôm qua tôi có cuộc họp chính thức với Ban Hành Giáo ở đây, nhưng vắng mặt 8 thành viên. Chúa nhật tới, tôi tổ chức Đại hội Gia đình phạt tạ Thánh Tâm, xin tất cả các thành viên Hội Thánh Tâm tham gia. Xin anh chị em hãy tham gia các hoạt động của hội hằng tuần, đây là vai trò phục vụ giáo xứ của anh chị em.

Thứ tư: xin anh chị em hãy cộng tác mật thiết với giáo xứ. Trước hết là cộng tác với Cha, thầy, sơ và Ban hành giáo bằng cách tham gia đóng góp ý kiến xây dựng giáo xứ. Xin quý thầy, quý sơ về đây họp với Cha hàng tháng để chia sẻ thông tin và công việc trong hạt cách rõ ràng. Quý tu sĩ có vai trò là người lãnh đạo trong sự cộng tác với linh mục, chứ không làm việc độc lập theo từng nơi. Linh mục là người duy trì sự đồng thuận nhất quán trong hạt. Tiếp theo, bởi sự cộng tác này, toàn Giáo hạt phải cộng tác chặt chẽ với Giáo phận, nghĩa là gần

gũi với Đức Giám Mục, vì Giáo hạt này thuộc quyền Giáo Phận Phnompenh, không phải là 1 chi nhánh của giáo hội Việt Nam.

Thứ năm: tôi mời gọi anh chị em tiếp tục tính toán về tương lai cho con em, đặc biệt là các bậc phụ huynh của các em đang đi học. Xin tổ chức việc học rõ ràng tại mỗi nơi. Chúng ta đã có các lớp: Mẫu giáo, lớp 1 và lớp 2. Nay thế giới đã bước sang thế kì 21, vì vậy hãy để cho con em mình hội nhập vào thế kỉ này nhờ việc học hành, là con đường duy nhất giúp cho các em có tương lai tốt. Xin đừng bắt con cái nghỉ học phụ giúp công việc nhà. Tôi thấy ở vài nơi có trẻ em 13-14 tuổi phải đi làm giúp gia đình: lượm ép chai, làm chả cá, làm khô,… Dù cực khổ cỡ nào, xin anh chị em hãy suy nghĩ về việc học hành của con cháu mình, vì nếu họ được học hành thì họ sẽ có 1 tương lai tốt. Trong cộng đồng người Khmer cũng vậy, người ta cho con nghỉ học để đi làm theo các xí nghiệp vì nghĩ là sẽ có tiền ngay, nhưng các xưởng, xí ngiệp không đem lại tương lai lâu bền. Vậy nên người Ki-tô hữu phải biết khôn ngoan. Tất cả các em nơi đây đều muốn có 1 tương lai tươi sáng, chẳng ai muốn có 1 đời cơ cực. Thế thì, xin anh chị em là những bậc làm cha, làm mẹ, ông bà: hãy tỉnh táo! Đồng thời xin hãy thúc đẩy con em cố gắng học hành mong rằng sẽ có tương lai hơn.

Thứ sáu: chúng ta hãy trở thành dấu chỉ của sự tha thứ của Thiên Chúa trong giáo xứ, trong gia đình và trong xã hội. Tôi tin rằng, ở trong giáo xứ, đôi khi cũng xảy ra cãi vã, Ban hành giáo không hài lòng về nhau,… nhưng chúng ta phải hòa giải với nhau, bởi vì Đức Giê-su, Chúa chúng ta, Ngài ngự đến để tha thứ cho chúng ta. Vì vậy, chúng ta cũng phải tha thứ cho nhau. Trong gia đình cũng thế, đôi lúc chúng ta không nhìn mặt nhau, cha mẹ mâu thuẫn với con cái, vợ chồng bất hòa với nhau,… nhưng Thiên Chúa đến để ta biết tha thứ cho nhau.

Thứ bảy: chúng ta phải luôn quan tâm đến công tác bác ái. Trước cửa nhà thờ có ghi bằng chữ khmer: “Thiên Chúa là tình yêu”. Vì thế, cuộc đời người Ki-tô hữu phải biết yêu thương và san sẻ tình yêu đó cho anh chị em trong giáo xứ của chúng ta. Nhưng tôi xin nhắc nhở rằng: hãy tiếp nối tình yêu đó đến tất cả mọi người. Vì trong hạt Basac của chúng ta có những giáo họ mới được thành lập tại 6 làng mới nữa. Nên chúng ta phải làm thế nào để thông qua việc bác ái, loan báo Tin Mừng cho những người anh em khác? Đặc biệt là những người anh em Khmer, là chủ của đất nước này. Gần đây, anh chị em đã thực

thi bác ái nhiều lắm rồi, nhưng công tác bác ái không bao giờ là đủ. Thế nên, tôi mời gọi anh chị em hãy thi hành ngày càng nhiều hơn nữa, để Lòng Thương Xót Chúa được mang đến mọi nơi anh chị em sống, vượt ra ngoài ranh giới giáo xứ mà đến khắp nơi.

Thứ tám: điều cuối cùng, xin cho tất cả chúng ta, những giáo xứ trong hạt Basac trở nên dấu chỉ bình an đích thật trong một xã hội đang vắng bóng hòa bình. Đặc biệt, giờ đây, tôi xin các em thanh thiếu niên sắp lãnh nhận Bí Tích Thêm sức luôn nhận ra rằng: Chúa Thánh Thần là bình an của Thiên Chúa, xin hãy chia sẻ bình an trong đời sống hàng ngày, như Thánh Phao-lô đã nói: “chúng ta phải dạy bảo người khác với lòng khiêm nhu vô hạn, vậy hãy cố gắng có lòng khiêm nhường mà chúng ta được đón nhận từ chính Thiên Chúa”.

Anh chị em thân mến! Tôi xin tạ ơn Thiên Chúa về sự trong sáng của các giáo xứ trong hạt Basac. Tạ ơn Chúa vì có Cha Tính, quý thầy, quý sơ, và toàn thể anh chị em chú tâm đến việc yêu mến, phục vụ và cầu nguyện. Tôi sẽ luôn cầu nguyện cho anh chị em và xin anh chị em cũng cầu nguyện cho giáo hội của chúng ta. Xin Chúa Thánh Thần soi sáng chúng ta, để chúng ta cùng xây dựng Hội Thánh.

Hoan hô giáo hạt Basac! Amen.

រៀបចំដោយ

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក (ភូមិភាគភ្នំពេញ)

ផ្ទះលេខ២៥ ផ្លូវលេខ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានីភ្នំពេញ

**Tel/Fax : (855) 23 224 120**

**Email : catholicphnompenh@gmail.com**

**Website : www.catholicphnompenh.org**

**Facebook page : www.facebook.com/catholicphnompenh**

Formation, Dialogue, Cooperation



ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦